# មេរៀនទី ២៨៖ ព្រះបង្កើតអ័ដាម និងអេវ៉ា

## លោកុប្បត្តិ ២៖៤-២២

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/wt-UXG8vF9o

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/rTFLnPbEqT8

**គោលបំណង៖** ព្រះបង្កើតយើងរាល់គ្នា។

**ខគម្ពីរចងចាំ៖ លោកុប្បត្តិ ២៖៧** *"ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់យកធូលីដីមកសូនធ្វើជាមនុស្ស ទ្រង់ផ្លុំខ្យល់ដង្ហើមជីវិតបញ្ចូលទៅក្នុងរន្ធច្រមុះ នោះក៏ត្រឡប់ជាមានព្រលឹងរស់ឡើង។"*

**ចំរៀង** ( *យូធូបលីង* )៖

១. នេះគឺជាថ្ងៃ https://youtu.be/zEHvnd9upD0

២. គឺជាការល្អ https://youtu.be/8K1SSE4KGYM

៣. ក្ដីសុខសាន្ដ https://youtu.be/N9mBBb9zljw

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «ស្គាល់ឈ្មោះ»




សម្ភារៈដែលត្រូវការ៖ បាល់តូចមួយ

១. ឲ្យកុមារឈរជាជរង្វង់

២. ជុំទី១៖ សិស្សត្រូវនិយាយឈ្មោះរបស់គេ ហើយបោះបាល់ទៅកុមារណាម្នាក់។ ប្រសិនបើកុមារណា ម្នាក់ បោះបាល់ដោយមិនបាននិយាយឈ្មោះរបស់ខ្លួនឯង នោះគេមិនអាចលេងល្បែងនេះបានទេ។

៣. ជុំទី២៖ កុមារត្រូវនិយាយឈ្មោះខ្លួនឯង ហើយបោះបាល់ទៅកុមារណាម្នាក់ ដោយនិយាយឈ្មោះកុមារម្នាក់នោះផងដែរ។ ប្រសិនបើកុមារនិយាយឈ្មោះខុស នោះគេនឹងចាញ់ល្បែងនេះ។

៤. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ឈ្មោះរបស់យើងម្នាក់ៗគឺពិសេស ដោយព្រោះតែព្រះជាអ្នកបង្កើតពួកយើង។

### ៤. ការណែនាំមេរៀន

ប្រសិនបើអ្នកអាចបង្កើតនូវអ្វីមួយដែលថ្មីនៅក្នុងពិភពលោកនេះ តើអ្នកនឹងបង្កើតអ្វី? តើអ្នកនឹងបង្កើតសត្វដែលមានជើង៦ឬ? ឬក៏ផ្កាចេះនិយាយ? ឬក៏ពពកដែលអាចទៅតាមអ្នកគ្រប់ទីកន្លែងបាន? នៅពេលដែលព្រះបង្កើតមនុស្សព្រះអង្គបានបង្កើតដោយពិសេសបំផុត។ ថ្ងៃនេះយើងនឹងរៀនពីរបៀបដែលព្រះបានបង្កើតយើង តាមវិធីដ៏ពិសេសបំផុត!

### ៥. រឿងនៅក្នុងព្រះគម្ពីរ

បន្ទាប់ពីព្រះបានបង្កើតពន្លឺ ដី មេឃ រុក្ខជាតិ ព្រះចន្ទ ព្រះអាទិត្យ ផ្កាយ បក្សី និងសត្វ សព្វសារពើហើយព្រះអង្គក៏បានយកចិត្តទុកដាក់ជាពិសេសក្នុងការបង្កើតមនុស្ស។ គ្រប់របស់ទាំងអស់ព្រះបានបង្កើតឡើងដោយគ្រាន់តែទ្រង់មានបន្ទូលប៉ុណ្ណោះ។ ព្រះបានមានបន្ទូលថា "ចូរឲ្យមានពន្លឺកើតឡើង" ហើយនោះ

ក៏មានពន្លឺកើតឡើងមែន។ លោកុប្បត្តិ ១៖២០ ព្រះបានមានបន្ទូលថា “ចូរឲ្យមានមច្ឆាជាតិរើក នៅក្នុងទឹកជាបរិបូរ និងបក្សីជាតិហើរលើដីនៅនាអាកាស” ហើយគ្រប់យ៉ាងក៏បានកើតឡើងដោយគ្រាន់តែព្រះមានបន្ទូលប៉ុណ្ណោះ។

ប៉ុន្តែនៅថ្ងៃទី ៦ លោកុប្បត្តិ ១៖២៦ “ ទ្រង់ក៏មានព្រះបន្ទូលថា ចូរយើងធ្វើមនុស្សឲ្យដូចជារូបយើងឲ្យមានភាពដូចយើង ហើយឲ្យមានអំណាចលើត្រីសមុទ្រ សត្វហើរលើអាកាស និងសត្វជើង៤ ដែលនៅលើផែនដីទាំងមូល ព្រមទាំងសត្វលូនវារដែលវារនៅលើផែនដីផង។”

ព្រះបានបង្កើតមនុស្សឲ្យដូចជារូបអង្គទ្រង់ នេះគឺមានន័យថា យើងអាចយល់ពីព្រះហឫទ័យទ្រង់បាន។ ហើយព្រះអង្គក៏បានឲ្យសិទ្ធិអំណាច ទៅមនុស្សជាអ្នកមើលការខុសត្រូវលើរបស់សព្វសារពើដែលទ្រង់បានបង្កើតមកផងដែរ! តើនេះមិនអស្ចារ្យពេកទេឬអី? មិនត្រឹមតែប៉ុណ្ណោះ ជំនួសឲ្យការដែលទ្រង់ គ្រាន់តែមានបន្ទូលហើយរបស់ទាំងអស់នោះកើតឡើង លោកុប្បត្តិ ២៖៧ ក៏បានចែងថា “ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់យកធូលីដីមកសូនធ្វើជាមនុស្ស ទ្រង់ផ្លុំខ្យល់ដង្ហើមជីវិតបញ្ចូលទៅក្នុងរន្ធច្រមុះ នោះក៏ត្រឡប់ជាមានព្រលឹងរស់ឡើង។”

ព្រះបានបង្កើតយើងឡើងដោយព្រះហស្តរបស់ទ្រង់! នេះគឺមានន័យថា មិនថាយើងមានរូបរាងយ៉ាងណានោះទេ ពួកយើងគឺជាមនុស្សពិសេសដោយព្រោះព្រះជាអ្នកបង្កើតយើងមក! ហើយព្រះបានផ្លុំខ្យល់ដង្ហើមមកក្នុងខ្លួនយើង ដើម្បីឲ្យយើងមានជីវិតរស់ឡើង។ នេះគឺជាការបង្កើតដ៏អស្ចារ្យ ពីព្រោះថាគ្មានការបង្កើតណាមួយដែលទ្រង់បានផ្លុំខ្យល់ដង្ហើមឱ្យនោះទេ!

បន្ទាប់មកព្រះបានប្រាប់ទៅអ័ដាមឲ្យដាក់ឈ្មោះសត្វទាំងអស់។ អ័ដាមបានឃើញថា សត្វទាំងអស់គឺមានមិត្តភក្តិ និងក្រុមគ្រួសារ។ ព្រះបានដឹងថា អ័ដាមនៅម្នាក់ឯងគឺឯកាណាស់ ដូច្នេះព្រះបានដកយកឆ្អឹងជំនីរបស់ អ័ដាម ហើយបានបង្កើតស្ត្រីម្នាក់សម្រាប់គាត់។ ព្រះបានដកយកឆ្អឹងជំនីអ័ដាម - ពីចំហៀងខ្លួនរបស់គាត់ - ដើម្បីបង្កើតអេវ៉ា នេះគឺបញ្ជាក់ថាបុរសមិនខ្ពង់ខ្ពស់ជាងស្ត្រីនោះទេ ហើយពួកគេត្រូវជួយគ្នាទៅវិញទៅមក។ ម្យ៉ាងទៀត ដោយព្រោះតែអ័ដាមបានឲ្យឆ្អឹងជំនីរបស់គាត់ដើម្បីបង្កើតជាអេវ៉ា ដូច្នេះគាត់មិនអាចពេញលក្ខណៈបានទេ ប្រសិនបើគ្មានអេវ៉ានោះ។ ក៏ដូចគ្នានេះ អេវ៉ាបានកើតចេញពីអ័ដាម ដូច្នេះប្រសិនបើគ្មានអ័ដាមទេ អេវ៉ាក៏មិនពេញលក្ខណៈដែរ។ ព្រះចង់ឲ្យអ័ដាម និងអេវ៉ាស្រលាញ់គ្នាទៅវិញទៅមក និងបង្កើតគ្រួសាររបស់ព្រះជាមួយគ្នា ឲ្យដូចជាពួកគេស្រលាញ់ព្រះ និងទទួលបានសេចក្តីស្រលាញ់ដែលព្រះបានប្រទានមកដល់ពួកគេផងដែរ។

នៅពេលដែលយើងក្រលេកមើលគ្រប់គ្នានៅក្នុងថ្នាក់រៀននេះ យើងឃើញថាម្នាក់ៗមានមុខមាត់ខុសៗគ្នា សិល្បៈនៃការបង្កើតខុសៗគ្នា។ សូមអ្នកសាកពិចារណាមើលថា មានមនុស្សប៉ុន្មានពាន់លាននាក់ដែលរស់នៅលើពិភពលោកនេះ។ ព្រះបានបង្កើតមនុស្សម្នាក់ៗតាមទម្រង់ និង លក្ខណៈប្លែកៗពីគ្នា។ ហើយនេះគឺជាការងារមួយដែលមានភាពច្នៃប្រឌិតខ្ពស់បំផុត! ព្រះមានអំណាចដ៏អស្ចារ្យ។ យើងគឺជាភស្តុតាងបញ្ជាក់ថាព្រះពោរពេញទៅដោយអំណាច ការច្នៃប្រឌិត និងសេចក្តីស្រលាញ់។ ព្រះបានបង្កើតយើងមកដោយសេចក្តីស្រលាញ់ ហើយទ្រង់ចង់ឲ្យយើងស្រលាញ់ព្រះអង្គ និងទទួលបានសេចក្តីស្រលាញ់ពីទ្រង់ផងដែរ!

## ៦. សំនួរពិភាក្សា

១. តើព្រះបានបង្កើតអ័ដាម(មនុស្ស)ដោយរបៀបណា? *( ព្រះទ្រង់យកធូលីដីមកសូនធ្វើជាមនុស្ស ទ្រង់ផ្លុំខ្យល់ដង្ហើមជីវិត នោះក៏ត្រឡប់ជាមានព្រលឹងរស់ឡើង)*

២. តើយើងអាចមើលឃើញអំណាច ការច្នៃប្រឌិត និងការបង្កើតមនុស្សរបស់ព្រះដោយរបៀបណា?
*(ព្រះបានបង្កើតមនុស្សដ៏ល្អនិងមានទម្រង់ខុសៗគ្នា)*
៣. តើអ្នកអាចបង្ហាញពីលក្ខណៈពិសេសរបស់អ្នកដែលព្រះបានបង្កើតដែរឬទេ?
*(ទុកឲ្យកុមារជាអ្នកឆ្លើយ)*

**៧. ល្បែងកំសាន្ត** **«លាក់មុខ»**




សម្ភារៈដែលត្រូវការ៖ ភួយ
១. ចែកកុមារជាពីរក្រុមហើយឲ្យកុមារអង្គុយទល់មុខគ្នា
២. គ្រូនិងឈរនៅកណ្ដាលដោយដាក់ភួយនៅកណ្ដាលផងដែរ ដើម្បីកុំឲ្យក្រុមទាំងពីរមើលគ្នាឃើញ
៣. ក្រុមទាំងពីរត្រូវជ្រើសរើសកុមារណាម្នាក់ពីក្រុមទាំងពីរ មកខាងមុខ ជិតភួយដោយស្ងៀមស្ងាត់។ នៅពេលដែលគ្រូរាប់ ១ ២ ៣ គ្រូនិងដាក់ភួយចុះ ហើយកុមារទាំងពីរត្រូវហៅឈ្មោះគ្នាទៅវិញទៅមក ឱ្យបានលឿន។ ប្រសិនបើគេហៅឈ្មោះបានត្រូវ និងលឿនជាងនោះគេនឹងទទួលបានមួយពិន្ទុ។
៤. ក្រុមណាដែលមានពិន្ទុច្រើនជាងគេក្រុមនោះជាអ្នកឈ្នះ។
៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ព្រះបានបង្កើតយើងទាំងអស់គ្នា ហើយដាក់ឈ្មោះដល់យើងគ្រប់ៗគ្នា។ ទោះបីជាយើងភ្លេចឈ្មោះមិត្តភក្តិរបស់យើងក៏ដោយ តែព្រះមិនភ្លេចឈ្មោះយើងទេ ពីព្រោះព្រះបានបង្កើតយើង!

**៨. ខគម្ពីរចងចាំ**

**លោកុប្បត្តិ ២៖៧** *"ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់យកធូលីដីមកសូនធ្វើជាមនុស្ស ទ្រង់ផ្លុំខ្យល់ដង្ហើមជីវិតបញ្ចូលទៅក្នុងរន្ធច្រមុះ នោះក៏ត្រឡប់ជាមានព្រលឹងរស់ឡើង។"*

**៩. ហាត្ថកម្ម សូមផាត់ពណ៌រូបភាព - "ព្រះបង្កើតអ័ដាម និងអេវ៉ា"**

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**
ព្រះបានបង្កើតយើងដោយលក្ខណៈពិសេស។ សូមចំណាយពេលបន្តិចដើម្បីអរព្រះគុណព្រះជាម្ចាស់សម្រាប់សិស្សរបស់អ្នក និងសម្រាប់វិធីដ៏ពិសេស និងស្រស់ស្អាតដែលទ្រង់បានបង្កើតពួកគេម្នាក់ៗឡើង។ តើមានវិធីអ្វីខ្លះដែលអ្នកអាចឲ្យពួកគេដឹងថាពួកគេសំខាន់ប៉ុណ្ណា? នៅពេលអ្នកឃើញសារៈសំខាន់ផ្ទាល់ខ្លួនរបស់អ្នកចំពោះព្រះ អ្នកអាចបំផុសគំនិតអ្នកដទៃឱ្យទទួលយកតម្លៃរបស់ពួកគេនៅក្នុងព្រះនេត្ររបស់ព្រះផងដែរ។

# ព្រះបង្កើតអ័ដាម និងអេវ៉ា



**លោកុប្បត្តិ ២៖៧** *“ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់យកធូលីដីមកសូនធ្វើជាមនុស្ស ទ្រង់ផ្លុំខ្យល់ដង្ហើមជីវិតបញ្ចូលទៅក្នុងរន្ធច្រមុះ នោះក៏ត្រឡប់ជាមានព្រលឹងរស់ឡើង។”*